# ក្រសួងមុខងារសាធារណៈ

## សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៣
## និងលើកទិសដៅការងារឆ្នាំ២០២៤

### ប្រធានបទ

## "ការលើកកម្ពស់ប្រសិទ្ធភាពការងារ"

បទបង្ហាញដោយ **លោកជំទាវ ឈី វិជ្ជរ៉ា** រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ
និង **ឯកឧត្តម សួន រស្មី** អគ្គលេខាធិការរង នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

០៣ មេសា ២០២៤

# មាតិកា

- សេចក្តីផ្តើម
- តួនាទី និងភារកិច្ច
- លទ្ធផលការងារ
- ទិសដៅការងារ
- សេចក្តីសន្និដ្ឋាន


ក្រៅពី "ការកែទម្រង់ការប្រឡងជ្រើសរើសមន្ត្រីរាជការ តាមរយៈ
ការដាក់ឱ្យអនុវត្តប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារប្រកបដោយគុណាធិបតេយ្យ
តម្លាភាព យុត្តិធម៌ បរិយាប័ន្ន និងប្រសិទ្ធភាព "
កិច្ចការដែលជាអាទិភាពគន្លឹះមួយផ្សេងទៀត របស់ក្រសួងមុខងារសាធារណៈ
គឺ "ការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពការងារ
ប្រកបដោយ វិន័យ សីលធម៌ វិជ្ជាជីវៈ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព "
នាយករដ្ឋមន្ត្រី
សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# តើធ្វើដូចម្តេចដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ?

ប្រមាណ ៦០% នៃនិយោជិតមិនដឹងអំពីគោលបំណង ឬបេសកកម្មរបស់ស្ថាប័នខ្លួន

# ក្របខណ្ឌប្រសិទ្ធភាពស្ថាប័នរបស់ Gallup



# ៣ កម្រិតនៃសមត្ថភាព



# យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១



# អនុលោមតាមៈ

- ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា (គ.វ.រ)
- អនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីតួនាទី និងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈក្នុងក្របខណ្ឌជាលេខាធិកាដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា
- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ១២៥ សសរ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតអនុគណៈកម្មាធិការប្រតិបត្តិ និងក្រុមការងារបច្ចេកទេស នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

ក្រុម.បច្ចេកទេសលើកកម្ពស់ប្រសិទ្ធភាពការងារ

**អនុគណៈកម្មាធិការប្រតិបត្តិនៃគ.ច.រ**

ក្រុម.បច្ចេកទេសរៀបចំប្រព័ន្ធលើកទឹកចិត្តសមិទ្ធកម្ម

ក្រុម.បច្ចេកទេសកែលម្អប្រព័ន្ធ ជ្រើសរើសមន្ត្រី

## តួនាទី និងភារកិច្ចរបស់ក្រុមការងារបច្ចេកទេសការលើកកម្ពស់ប្រសិទ្ធភាពការងារនៃអនុគណៈកម្មាធិការប្រតិបត្តិនៃគ.វ.រ មានដូចតទៅ៖

- ពិនិត្យ និងសិក្សាស្រាវជ្រាវស្ថានភាពបច្ចុប្បន្ន ឧត្តមានុវត្តន៍ និងនវានុវត្តន៍ នៃការរៀបចំរចនាសម្ព័ន្ធស្ថាប័ន មុខងារ របៀបរបបការងារនិងដំណើរការរដ្ឋបាល ការគ្រប់គ្រងនិងការប្រើប្រាស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យា ក្នុងរដ្ឋបាលសាធារណៈ

- រៀបចំនិងស្នើយុទ្ធសាស្ត្រ ផែនការសកម្មភាពការងារ កំណត់សូចនាករសមិទ្ធកម្ម ក្របខណ្ឌពេលវេលាអនុវត្ត ក្របខណ្ឌត្រួតពិនិត្យនិងវាយតម្លៃ ព្រមទាំងវិធីសាស្ត្រនិងមធ្យោបាយផ្សេងៗក្នុងការដាក់អនុវត្តវិធានការគន្លឹះរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាព និងសមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពប្រកបដោយ វិន័យសីលធម៌ វិជ្ជាជីវៈប្រសិទ្ធភាព និងសក្តិសិទ្ធិភាព

- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីអនុគណៈកម្មាធិការប្រតិបត្តិនៃគ.វ.រ ។

## លទ្ធផលការងាររបស់ក្រុមការងារបច្ចេកទេសការលើកកម្ពស់ប្រសិទ្ធភាពការងារ ក្នុងរយៈពេល៦ខែ នៃការអនុវត្តតួនាទី និងភារកិច្ច មានដូចតទៅ៖

- រៀបចំ និងកំណត់ផែនការសកម្មភាពការងារ២០២៤
- ពិនិត្យ និងរៀបចំផែនការយុទ្ធសាស្ត្រលើកកម្ពស់ប្រសិទ្ធភាពការងារ ២០២៤-២០២៨
- រៀបចំសេចក្តីព្រាងឯកសារទស្សនាទាន និងសេចក្តីណែនាំ ស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន
- រៀបចំសេចក្តីព្រាងឯកសារស្តីពីការរៀបចំប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការ និងការពង្រាយមន្ត្រី
- រៀបចំសេចក្តីព្រាងគម្រោងចំនួនពីរ៖ (១).ការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន (២).ការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការ

## លទ្ធផលការងាររបស់ក្រុមការងារបច្ចេកទេសការលើកកម្ពស់ប្រសិទ្ធភាពការងារ ក្នុងរយៈពេល៦ខែ នៃការអនុវត្តតួនាទី និងភារកិច្ច មានដូចតទៅ៖

- រៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈ និងក្រមប្រតិបត្តិមន្ត្រីសាធារណៈ
- រៀបចំសេចក្តីព្រាងឯកសារនិយាមនីតិវិធីប្រតិបត្តិសម្រាប់អង្គភាពកម្រិតអគ្គនាយកដ្ឋាន
- ជូនដំណឹងស្តីពីការចាត់បញ្ជូនមន្ត្រីនៃក្រសួង ស្ថាប័ន ចូលរួមធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការស៊ីវិល និងរៀបចំវគ្គបណ្តុះបណ្តាល
- ពិនិត្យរៀបចំក្រុមការងារដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការស៊ីវិល និងរៀបចំវគ្គបណ្តុះបណ្តាល។

# ទិសដៅការងារ

ការពិនិត្យឡើងវិញ ការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន

ផែនការយុទ្ធសាស្ត្រលើកម្ពស់ប្រសិទ្ធភាពការងារមន្ត្រី និងអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន( ថ្នាក់ជាតិ ) ២០២៤-២០២៨

ការលើកកម្ពស់ប្រសិទ្ធភាពប្រតិបត្តិការ

ការអភិវឌ្ឍសមត្ថភាព និងភាពជាអ្នកដឹកនាំ

# សេចក្តីសន្និដ្ឋាន

ដើម្បីសម្រេចបានប្រសិទ្ធភាពការងារនៅក្រសួង ស្ថាប័ន ចាំបាច់ត្រូវកំណត់នូវវិធានការការងារច្បាស់លាស់ ដោយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន និងការចូលរួមគាំទ្រអនុវត្តគោលការណ៍ សេចក្តីណែនាំ នីតិវិធី និងនិយាមប្រតិបត្តិការងារពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធដើម្បីទទួលបានប្រសិទ្ធភាព គុណភាព និងសមិទ្ធផលការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។

**សូមអរគុណ !**